នាយកដ្ឋាន ផ.ប

Australian Government
Australian Centre for International Agricultural Research

ACIAR

# គំរោង ” ការអនុវត្តន៍ល្អប្រសើរ លើការខារសុខភាព និង ផលិតកម្ម គោ នៅកម្ពុជា ”

**(Best Practice Health and Husbandry, Cattle, Cambodia ACIAR, AH/2005/086)**









**អនុវត្តគំរោង : នាយកដ្ឋានផលិតកម្ម និង បសុព្យាបាល**

**ឧបត្ថម្ភដោយ : មជ្ឈមណ្ឌលអូស្ត្រាលីស្រាវជ្រាវកសិកម្មអន្តរជាតិ (ACIAR)**


អាស័យដ្ឋាន :# ៧៤ មហាវិថីព្រះមុនីវង្ស សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ

ទូរស័ព្ទ/ទូរសារ : ៨៥៥ ០២៣ ៩៩១ ៨៣៩

E-mail: Sothoeundahp@online.com.kh

នៅប្រទេសកម្ពុជា ការចិញ្ចឹមគោ ក្របី មានសារៈសំខាន់យ៉ាងខ្លាំង ដោយសារតែសត្វទាំងនោះត្រូវបានចិញ្ចឹមដើម្បីៈ ១/ប្រើប្រាស់សម្រាប់ភ្ជួរ-រាស់ ទឹមរទេះ ដឹកជញ្ជូន ២/យកលាមកធ្វើជី ៣/ទ្រព្យបំរុង ៤/ប្រាក់ចំណូល ៥/ផ្គត់ផ្គង់សាច់និងវត្ថុធាតុដើមសម្រាប់ប្រើប្រាស់ក្នុងប្រទេស និងនាំចេញ។

ការចិញ្ចឹមគោ ក្របី ជាទូទៅជួបប្រទះនូវបញ្ហាមួយចំនួនដូចជា ការផ្តល់ចំណីអាហារមិនគ្រប់គ្រាន់ទាំងបរិមាណ និងគុណភាព ជំងឺឆ្លងរាតត្បាត មិនទាន់យកចិត្តទុកដាក់ខ្ពស់ និងខ្វះខាតបច្ចេកទេសចិញ្ចឹម-ថែទាំ ខ្វះខាតការជ្រើសរើសពូជ និងការបង្កាត់ពូជ ដែលជាលទ្ធផល ផលិតភាពសត្វនៅមានកំរិតទាប និងមិនសូវទទួលនូវប្រាក់ចំណេញ ។



**គោលបំណងរបស់គំរោង**

ជំរុញការអភិវឌ្ឍន៍ចិញ្ចឹម គោ ក្របី នៅកម្ពុជា អោយទទួលបានផលិតភាពខ្ពស់ បង្កើនផលចំណេញតាមរយៈវិធីសាស្ត្រអនុវត្តដ៏មានប្រសិទ្ធភាព និងតាមរយៈអន្តរាគមន៍នានា លើការងារគ្រប់គ្រង ចាត់ចែង ចិញ្ចឹម ថែទាំ និងបង្កាត់ពូជ។

**សកម្មភាពសំខាន់ៗរបស់គំរោង**

១. សិក្សាស្រាវជ្រាវ និងកំណត់ជំងឺសំខាន់ៗរបស់គោ ក្របី ។
២. សាកល្បងពិសោធន៍ និងអនុវត្តបង្ហាញ ការធ្វើអន្តរាគមន៍ការពារជំងឺសំខាន់ៗរបស់ គោ ក្របី ការពារការជ្រៀតចូល និង ឆ្លងរាលដាលជំងឺ ។









៣. សិក្សាស្រាវជ្រាវ  អង្កេត  ការងារចិញ្ចឹម  ថែទាំ ជ្រើសរើស បង្កាត់ពូជ និងការចាត់ចែងគ្រប់គ្រងចិញ្ចឹមសត្វ  ។

៤.  សិក្សាស្រាវជ្រាវ  អង្កេត  ការចាត់ចែង និងផ្តល់ចំណី គោ  ក្របី  ការសិក្សាអំពីប្រសិទ្ធភាពសេដ្ឋកិច្ច  លើការងារ អន្តរាគមន៏ ការងារអនុវត្តល្អប្រសើរលើការងារសុខភាព  និងផលិតកម្ម គោ ក្របី ។






៥. វាយតំលៃគោលជំហររបស់កសិករ ស្តីពីការងារសុខភាពសត្វ  ការចិញ្ចឹម  ថែទាំ និងបញ្ហាទីផ្សារសត្វ ។ ផ្សព្វផ្សាយ លទ្ធផលទាំងនេះដល់អ្នកពាក់ព័ន្ធ  ជាពិសេសកសិករម្ចាស់សត្វ  ។




៦. បង្កើនចំណេះដឹងស្តីពីប្រព័ន្ធផ្គត់ផ្គង់គោ ក្របី និងគន្លឹះសំខាន់ៗនៃផលិតកម្មគោ ក្របី ដល់កសិករ-ម្ចាស់សត្វ ។





៧. ផលិតឯកសារ ផលិតនិងបោះពុម្ពសៀវភៅស្តីពីជំងឺសំខាន់ៗ របស់គោ ក្របី ការចាត់ចែងផលិត និងផ្តល់ចំណីសត្វ ។

៨. ផលិតស្ពតវីដេអូ និង ស្ពតវិទ្យុស្តីពីការការពារជំងឺសំខាន់ៗ គោ ក្របី ការចិញ្ចឹម ថែទាំ បង្កាត់ពូជ ផលិត និងផ្តល់ចំណីសត្វ ។






ការស្រាវជ្រាវសុខភាព និងផលិតកម្ម គោ ក្របី តាមបែបវិទ្យាសាស្ត្រ និងការងារផ្សព្វផ្សាយបច្ចេកទេសចិញ្ចឹម ថែទាំ បង្កាត់ពូជ ព្រមទាំងការបណ្តុះបណ្តាលអោយចេះគិតគូរពីប្រសិទ្ធភាពសេដ្ឋកិច្ច ក្នុងគោលបំណងវិនិយោគមធ្យោបាយជំរុញ និងអភិវឌ្ឍន៍ផលិតកម្ម គោ ក្របី នៅកម្ពុជា ដែលអាចអនុវត្តបានដោយកសិករនឹងជួយបង្កើនប្រាក់ចំណូលក្នុងគ្រួសារ និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ។

## រយៈពេលអនុវត្តគំរោង

គំរោងមានរយៈពេល ៤ ឆ្នាំ ដោយអនុវត្តពី ខែ តុលា ២០០៧ ដល់ខែ ឧសភា ២០១១។

## ទំនាក់ទំនង

**បណ្ឌិត សួន សុធឿន**

អនុប្រធាននាយកដ្ឋាន ផលិតកម្ម និង បសុព្យាបាល នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

អាស័យដ្ឋាន : # ៧៤ មហាវិថីព្រះមុនីវង្ស សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ

ទូរស័ព្ទ/ទូរសារ : ៨៥៥ ០២៣ ៩៩១ ៨៣៩ និង E-mail: Sothoeundahp@online.com.kh